**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**

-សំណុំរឿងរដ្ឋប្បវេណីលេខ ១០៦
ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣
-សាលក្រមរដ្ឋប្បវេណីលេខ ៤៨ (ច)
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពត**

-បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ។
-កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤។

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកំពត

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

-ដើមចោទឈ្មោះ [redacted] ឡុងពោ ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ [redacted] ។

ដោយមានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ [redacted] ស្រីហ្គេច ភេទស្រី អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ [redacted] ។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

**អង្គហេតុ និងចំណុចវិវាទ**

ក-ខ្លឹមសារនៃសាលក្រមដែលភាគីទាមទារឱ្យតុលាការចេញ

ខ្លឹមសារនៃការទាមទារក្នុងបណ្តឹងដើម ៖ សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ស្រីហ្គេច ។

ខ្លឹមសារនៃការទាមទារក្នុងបណ្តឹងតប ៖

១-បែងចែងជាពីរចំណែកនូវទ្រព្យសម្បត្តិរួម ដូចខាងក្រោម៖

-ប្រាក់ចំនួន ២០.០០០(ពីរម៉ឺនដុល្លារអាមេរិក)ពីអាជីវកម្មលក់មាស ។

-ប្រាក់គុងទីនចំនួន ១៦០.០០០(មួយម៉ឺនប្រាំមួយពាន់ដុល្លារអាមេរិក) ។

-ប្រាក់ដែលបានពីរចំណែកដៃចំនួន ៣.០០០(បីពាន់ដុល្លារអាមេរិក) ។

២-បង្គាប់ឱ្យដើមចោទប្រគល់នូវខ្សែកមាសចំនួន ០១តម្លឹង និងចិញ្ចៀនពេជ្រចំនួន ០១វង់(ចិញ្ចៀនភ្ជាប់ពាក្យ) ជាទ្រព្យដោយឡែកមកឱ្យដើមបណ្តឹងតប ។

ខ-ការពន្យល់គ្រួសៗអំពីរឿងក្តី ៖

ដើមចោទ និងចុងចម្លើយបានរៀបការ និងរួមរស់ជាមួយចុងចម្លើយ រយៈពេលមួយឆ្នាំកន្លងមកហើយ ដើមចោទ និងចុងចម្លើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ ការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ពុំចុះសម្រុងនឹងគ្នាទេ ដោយមានបញ្ហាកើតឡើងជាញឹកញាប់ បណ្តាលមកពីចុងចម្លើយតែងតែមានសកម្មភាពរង់រក់ឥតឈប់ឈរ ស្ទើររាល់ពេលនៅជាមួយដើមចោទ ដែលសកម្មភាពនេះជាការរំខាន ដល់ជីវិតរស់នៅរបស់ដើមចោទយ៉ាងធ្ងន់ធ្ងរបំផុត ។

គ-ការអះអាងរបស់ភាគី ៖

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានថ្លែងការណ៍ថាៈ ទាក់ទងនឹងការទាមទារដែលជាចំណុចវិវាទដូចដែលខ្លួនបានលើកឡើងកាលពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺប្រាក់ដែលទាមទារនេះ ជាប្រាក់ដែលទទួលបានពីប្រាក់ចំណេញអាជីវកម្មលក់មាស ក្នុងអំឡុងពេលរស់នៅជាមួយគ្នា ដែលក្នុង ០១ខែ ចំណេញបានប្រហែលចំនួន ២.០០០(ពីរពាន់)ដុល្លារអាមេរិក ដូច្នេះសរុបមកបានចំនួន ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក ដោយការរស់នៅជាមួយគ្នាគិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ រហូតដល់ខែមេសា ឆ្នាំ២០២៣។

ចំពោះប្រាក់តុងទីន ឃើញថា មានឈ្មោះ [redacted] ឡេងពោ ក្នុងតារាងឈ្មោះអ្នកលេង ហើយការលេងនេះជាប្រាក់ដែលបានមកពីប្រាក់ចំណេញដែលគាត់រួមរស់នៅជាមួយគ្នា សរុបប្រាក់ប្រហែល ១៦.០០០ (មួយម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក។ កូនក្តីទាមទារចំណែកនៅអំឡុងពេលដែលរស់នៅជាមួយគ្នា ដោយសុំចែកជាពីរចំណែក គិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ខែមេសា ឆ្នាំ២០២៣។

រីឯប្រាក់ចងដៃចំនួន ៣.០០០(បីពាន់)ដុល្លារអាមេរិក កូនក្តីខ្លួនទាមទារចែកជាពីរចំណែក ហើយស្នើសុំតុលាការប្រកាសអនុវត្តបណ្តោះអាសន្នចំពោះចំណុចអត់មានវិវាទ ក្នុងការប្រគល់ខ្សែក និងប្រាក់តុងទីនន ព្រោះជិតដល់ពេលដេញបាន។ សុំរក្សាការអះអាងដែលមានក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

-ចុងចម្លើយបានអះអាងថាៈ ការលេងតុងទីនន ខ្លួនមិនដឹងថាបង់ប៉ុន្មានទេ ព្រោះដើមចោទជាអ្នកបង់ ដោយគាត់លេងខ្សែ ១.០០០(មួយពាន់)ដុល្លារអាមេរិក ចំនួន ០១ក្បាល ហើយនៅរស់។ ប្រាក់ចំនួន ៣.០០០ (បីពាន់)ដុល្លារអាមេរិក ជាប្រាក់គួចដៃ ហើយនៅលើដើមចោទជាអ្នកកាន់កាប់ ។

-លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថាៈ ខ្លួនសុំរក្សានៅពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៣ និងសុំរក្សាអ្វីដែលខ្លួនបានលើកឡើងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ខ្លួនសុំបដិសេធទាំងស្រុងទៅការទាមទារក្នុងពាក្យបណ្តឹងតបរបស់ចុងចម្លើយ ។ ខ្លួនសុំបញ្ជាក់ថា ប្រាក់អាជីវកម្មទាមទារ ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក គឺមិនពាក់ព័ន្ធនឹងកូនក្តីខ្លួនទេ វាជាអាជីវកម្មរបស់ម្តាយកូនក្តី មិនមានភស្តុតាងណាដែលអាចបញ្ជាក់បានថាអាជីវកម្មនេះជារបស់កូនក្តីខ្លួននោះទេ គ្រាន់តែកូនក្តីខ្លួន និងចុងចម្លើយមកជួយរកស៊ីដើម្បីជីវភាពប្រចាំថ្ងៃ ហើយក្រោយមកពួកគាត់រួមរស់នៅជាមួយគ្នាក៏បែកគ្នាទៅ។

ចំពោះតុងទីន ជាឈ្មោះរបស់កូនក្តី ប៉ុន្តែកូនក្តីលេងលុយរបស់ម្តាយ ជាទ្រព្យរបស់ម្តាយ ហើយបានលេងនៅមុនពេលដែលពីរនាក់ប្តីប្រពន្ធនេះរស់នៅជាមួយគ្នា ចំណែកចុងចម្លើយមិនបានដឹងផងថាបង់ប្រាក់យ៉ាងម៉េច ។ តុងទីននោះលេងក្បាល ១.០០០(មួយពាន់)ដុល្លារអាមេរិកពិតមែន។ រីឯប្រាក់ចំណងដៃចំនួន ៣.០០០(បីពាន់)ដុល្លារអាមេរិក កូនក្តីបានបញ្ជាក់ថា គឺចុងចម្លើយជាអ្នករក្សាទុក និងបានចាត់ចែងធ្វើធ្មេញដើរលេងក្នុងគ្រួសារ និងសងថ្លៃអីវ៉ាន់ទៅលើការទិញអីវ៉ានអស់ហើយ ។ ដូច្នេះស្នើសុំច្រានចោលបណ្តឹងតបពីព្រោះថាមិនពាក់ព័ន្ធនឹងកូនក្តីខ្លួននោះទេ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានថ្លែងការណ៍ថាៈ ស្នើសុំដូចមានក្នុងការទាមទារក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទាំងបីលើក។ សុំប្រគល់ខ្សែកមាសចំនួន ០២ខ្សែ ស្មើ ០១តម្លឹង មកឱ្យកូនក្តី ហើយប្រគល់ចិញ្ចៀនភ្ជាប់ពាក្យឱ្យទៅដើមចោទ និងសុំអនុវត្តបណ្តោះអាសន្នត្រង់ចំណុចប្រាក់តុងទីនន និងការប្រគល់ខ្សែក និងចិញ្ចៀនខាងលើ។



Scanned with CamScanner

ឃ-ចំណុចគ្មានវិវាទ និងចំណុចវិវាទ ៖

ឃ.១-ចំណុចវិវាទ៖

១-តើដើមចោទប្ដឹងសុំលែងលះពីចុងចម្លើយមានមូលហេតុត្រឹមត្រូវតាមច្បាប់ដែរឬទេ?

២-តើការប្ដឹងសុំរបស់ចុងចម្លើយបែងចែកទ្រព្យសម្បត្តិរួម នូវ ប្រាក់ពីអាជីវកម្មលក់មាសចំនួន ២០.០០០ (ពីរម៉ឺន)ដុល្លារអាមេរិក, ប្រាក់គុងទីនចំនួន ១៦០.០០០(មួយម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក និងប្រាក់ចំណងដៃចំនួន ៣.០០០(បីពាន់)ដុល្លារអាមេរិក ជាពីរចំណែកមានមូលហេតុត្រឹមត្រូវតាមច្បាប់ដែរឬទេ?

ឃ.២-ចំណុចគ្មានវិវាទ៖

-គូភាគីបានព្រមព្រៀងគ្នា ដោយភាគីដើមចោទយល់ព្រមប្រគល់នូវ ខ្សែកមាសចំនួន ០២ខ្សែ ទម្ងន់ ០១តម្លឹងដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ឱ្យទៅចុងចម្លើយ ហើយចុងចម្លើយយល់ព្រមឱ្យដើមចោទចាត់ចែងនូវ ចិញ្ចៀនពេជ្រចំនួន ០២វង់ដែលទទួល បានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

ង-ភស្តុតាងជាឯកសាររួមមាន ៖

-សំបុត្រអាពាហ៍ពិពាហ៍លេខ ២៦ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០២២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំម៉ាក់ប្រាង្គ ។

-តារាងសមាជិកសមាគមន៍ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ។

**សំអាងហេតុ**

ពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] ឡេងពោ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៣ និងពាក្យបណ្ដឹងតបរបស់ឈ្មោះ [redacted] ស្រីហ៊ុច ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ ធ្វើឡើងស្របតាមទម្រង់ច្បាប់ដែលអាចឱ្យតុលាការពិចារណា និងសម្រេចបាន។ ក្រោយពីបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងពិនិត្យភស្តុតាងក្នុងសំណុំរឿងរួចឃើញថា:

១-ផ្អែកតាមការអះអាងរបស់គូភាគី និងសំបុត្រអាពាហ៍ពិពាហ៍លេខ ២៦ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០២២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំម៉ាក់ប្រាង្គ បញ្ជាក់បានថាដើមចោទ និងចុងចម្លើយពិតជាបានរៀបការ និងចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ប្រាកដមែន ហើយតាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ បង្ហាញថាក្នុងអំឡុងពេលរួមរស់ជាមួយគ្នារយៈពេល ១(មួយ)ឆ្នាំ និង ៨(ប្រាំបី)ខែ ដើមចោទ និងចុងម្លើយពិតជាមានភាពកាំរកូស មិនចុះសម្រុងនឹងគ្នា ដែលជាមូលហេតុធ្វើឱ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្ដីប្រពន្ធបន្តទៅទៀត ។ តុលាការបានព្យាយាមក្នុងការផ្សះផ្សា ប៉ុន្តែគូភាគីមិនយល់ព្រមក្នុងការរួមរស់នឹងគ្នាជាប្ដីប្រពន្ធបន្តទៀតឡើយ ដូច្នេះគប្បីតុលាការសម្រេចឱ្យលែងលះស្របតាមបញ្ញត្តិមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

២-តាមការអះអាងរបស់ដើមចោទ(ចុងបណ្ដឹងតប) និងចុងចម្លើយ(ដើមបណ្ដឹងតប) នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឃើញថា ភាគីបានព្រមព្រៀងគ្នា ដោយភាគីដើមចោទយល់ព្រមប្រគល់នូវ ខ្សែកមាសចំនួន ០២ខ្សែ ទម្ងន់ ០១តម្លឹងដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ឱ្យទៅចុងចម្លើយ ហើយចុងចម្លើយយល់ព្រមឱ្យដើមចោទចាត់ចែងនូវ ចិញ្ចៀនពេជ្រចំនួន ០២វង់ដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ដូច្នេះតុលាការគប្បីសម្រេចបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀងរបស់គូភាគី ស្របតាមបញ្ញត្តិមាត្រា៩៨០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ។



Scanned with CamScanner

៣-លោក[redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានថ្លែងការណ៍ថា: ប្រាក់ដែលទាមទារនេះ ជាប្រាក់ដែលទទួលបានពីប្រាក់ចំណេញអាជីវកម្មលក់មាស ក្នុងអំឡុងពេលរស់នៅជាមួយគ្នាដែលក្នុង ០១ខែ ចំណេញបានប្រហែលចំនួន ២.០០០(ពីរពាន់)ដុល្លារអាមេរិក ដូច្នេះសរុបមកបានចំនួន ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក ដោយការរស់នៅជាមួយគ្នាគិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ រហូតដល់ខែមេសា ឆ្នាំ២០២៣។ ចំណុចនេះលោកស្រី [redacted] ឈូន ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា ប្រាក់អាជីវកម្មទាមទារ ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក គឺមិនពាក់ព័ន្ធនឹងកូនក្តីខ្លួនទេ វាជាអាជីវកម្មរបស់ម្តាយកូនក្តី មិនមានភស្តុតាងណាដែលអាចបញ្ជាក់បានថាអាជីវកម្មនេះ ជារបស់កូនក្តីខ្លួននោះទេ គ្រាន់តែកូនក្តីខ្លួន និងចុងចម្លើយមកជួយរកស៊ីដើម្បីជីវភាពប្រចាំថ្ងៃ ។ តុលាការយល់ឃើញថា ការទាមទារប្រាក់ចំណេញពីអាជីវកម្មដោយចុងចម្លើយនេះ មិនមានភស្តុតាងណាបញ្ជាក់ឡើយ ដូច្នេះតុលាការមិនមានមូលដ្ឋានពិចារណាឡើយ គប្បីសម្រេចច្រានចោលការទាមទារ ។

រីឯការទាមទារប្រាក់ចំណងដៃចំនួន ៣.០០០(បីពាន់)ដុល្លារអាមេរិករបស់ចុងចម្លើយ ដែលថានៅលើដើមចោទជាអ្នកកាន់កាប់ គឺមានការទទួលស្គាល់ពីភាគីដើមចោទថាពិតជាមានមែន ប៉ុន្តែដើមចោទបានបញ្ជាក់ថាប្រាក់នេះត្រូវបានចុងចម្លើយធ្វើការចាត់ចែងអស់ហើយ តុលាការយល់ឃើញថា ការទាមទាររបស់ចុងចម្លើយនេះ មិនមានភស្តុតាង ឬមូលដ្ឋានក្នុងការទាមទារដែលអាចឱ្យតុលាការពិនិត្យឡើយ ដូច្នេះគប្បីតុលាការសម្រេចច្រានចោលការទាមទារ ។

៤-តាមសេចក្តីថ្លែងការណ៍របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយដែលថា ចំពោះប្រាក់តុងទីន ឃើញថា មានឈ្មោះ [redacted]ឡុងពោ ក្នុងតារាងឈ្មោះអ្នកលេង ហើយការលេងនេះជាប្រាក់ដែលបានមកពីប្រាក់ចំណេញដែលគាត់រួមរស់នៅជាមួយគ្នា សរុបប្រាក់ប្រហែល ១៦.០០០ (មួយម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក កូនក្តីទាមទារចំណែកនៅអំឡុងពេលដែលរស់នៅជាមួយគ្នា ដោយសុំចែកជាពីរចំណែក គិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ខែមេសា ឆ្នាំ២០២៣ ។ តុលាការយល់ឃើញថា តាម ភស្តុតាង តារាងសមាជិកសមាគមន៍ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ដែលមានឈ្មោះ[redacted] សោភណ្ឌារី ជាប្រធាន បង្ហាញថាមានឈ្មោះ[redacted]ឡុងពោ ក្នុងតារាងឈ្មោះអ្នកលេង ចំនួន ០១ក្បាល ។ ចំពោះការឆ្លើយបដិសេធរបស់ភាគីដើមចោទ មិនមានភស្តុតាងណាបញ្ជាក់បានឡើយ តុលាការមិនពិចារណា ។ ដោយឡែកនៅក្នុងការអះអាងគឺភាគីទទួលស្គាល់ថាការលេងតុងទីនក្បាល ១.០០០(មួយពាន់)ដុល្លារអាមេរិក ។ ផ្អែកតាមភស្តុតាង តារាងសមាជិកសមាគមន៍ដដែល និងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០២២ គប្បីតុលាការទទួលស្គាល់អំពីអំឡុងពេលដែលត្រូវគណនានូវប្រាក់តុងទីនក្នុងការទាមទារចាប់ពីខែមិថុនា ឆ្នាំ២០២២ រហូតដល់ពេលបែកលំនៅសង្វាសខែមេសា ឆ្នាំ២០២៣ ។ ដូច្នេះ គប្បីតុលាការសម្រេចតាមការទាមទាររបស់ចុងចម្លើយក្នុងទំហំនៃសិទ្ធិទាមទារដែលទទួលស្គាល់ដោយច្បាប់ គិតចាប់ពីខែមិថុនា ឆ្នាំ២០២២ រហូតដល់ខែមេសា ឆ្នាំ២០២៣ សរុបស្មើនឹងប្រាក់ចំនួន ១១.០០០(មួយម៉ឺនមួយពាន់)ដុល្លារអាមេរិក ស្របតាមបញ្ញត្តិមាត្រា៩៨០ កថាខណ្ឌទី២ ចំណុច ខ នៃក្រមរដ្ឋប្បវេណី រីឯការទាមទារលើសពីនេះត្រូវច្រានចោល ។

៥-ភាគីចុងចម្លើយបានប្តឹងសុំនៅកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ សុំប្រកាសអនុវត្តជាបណ្តោះអាសន្នចំពោះការប្រគល់ខ្សែក និងប្រាក់តុងទីន តុលាការមិនធ្វើការពិចារណា ដោយសារជាការ



Scanned with CamScanner

ប្តឹងសុំនេះមានលក្ខណៈផ្ទុយច្បាប់ និងមិនមានភាពចាំបាច់ក្នុងការសម្រេចអំពីការប្រកាសអនុវត្តជាបណ្តោះអាសន្នស្របតាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៦-ប្រាក់ប្រដាប់ក្តីអនុវត្តតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**សេចក្តីសម្រេចបញ្ចប់**

១-ឈ្មោះ [redacted] ឡេងពោ លែងលះពីឈ្មោះ [redacted] ស្រីហ្គេច ចាប់ពីពេលសាលក្រមចូលជាស្ថាពរតាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

២-ដើមចោទ និងជាចុងចម្លើយតបឈ្មោះ [redacted] ឡេងពោ ធ្វើលទ្ធកម្មកម្មសិទ្ធិលើចិញ្ចៀនពេជ្រចំនួន ០២ វង់ ដែលទទួលបានក្នុងពេលរៀបអាពាហ៍ពិពាហ៍ តាមការព្រមព្រៀងរបស់គូភាគី ។

៣-បង្គាប់ឱ្យដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ឡេងពោ ប្រគល់ឱ្យទៅចុងចម្លើយ និងជាដើមបណ្តឹងតបនូវ ខ្សែកមាសចំនួន ០២ខ្សែ ស្មើនឹងទម្ងន់ ១ តំឡឹង ដែលទទួលបានក្នុងពេលរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀងរបស់គូភាគី ។

៤-បែងចែកជាពីរចំណែកស្មើគ្នា នូវប្រាក់លេងតុងទីនជាមួយនឹងប្រធានឈ្មោះ [redacted] សោភណ្ឌារី ចំនួន ០១ ក្បាល ដែលមានកូនតុងទីនឈ្មោះ [redacted] ឡេងពោ គិតចាប់ពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ ចំនួន ១១.០០០ (មួយម៉ឺនមួយពាន់) ដុល្លារអាមេរិក ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

៥-ច្រានចោលការទាមទារចែកជាពីរចំណែករបស់ចុងចម្លើយ និងជាដើមបណ្តឹងតបនូវ៖

៥.១.ប្រាក់ចំណេញពីជាជីវកម្មលក់មាសចំនួន ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក។

៥.២.ប្រាក់ចំណងដៃចំនួន ៣.០០០(បីពាន់)ដុល្លារអាមេរិក ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

ថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពត, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពត, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner